ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៥៧២១...សហវ.ក្របក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្រគល់មុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក
- អនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- អនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- ប្រកាសអន្តរក្រសួងលេខ៥០៨ សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា
- លិខិតលេខ៨០១៥ សហវ.អថ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលគោលការណ៍ចំណាយមួយចំនួនសម្រាប់អនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ សាលាគរុកោសល្យនិងវិក្រឹត្យការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តចាប់ពីឆ្នាំ២០១៩ តទៅ

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង ដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំងនេះ។

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅកំណត់លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តនៅរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង ក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដោយមានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ជាសេនាធិការ និងមានគ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ជាអង្គភាពអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ នេះ។

## ជំពូកទី ២
## សិទ្ធិអំណាច ការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងការគ្រប់គ្រងថវិកា

**ប្រការ ៤.-**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងស្ថាប័ននីតិប្បញ្ញត្តិលើវិស័យអប់រំ។

ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាង

លទ្ធផលចំពោះរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលបានប្រគល់ឱ្យស្របតាមគោលនយោបាយអាទិភាពវិស័យអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីកែទម្រង់វិស័យអប់រំ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងត្រូវមានគណនេយ្យភាពចំពោះប្រជាជនក្នុងការផ្តល់សេវាអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ដែលមានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ជាសេនាធិការត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាព ចំពោះក្រសួងអប់រំ យុវជន និងកីឡាតាមរយៈមន្ទីរអប់រំ យុវជន និងកីឡា លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកម្រិតមធ្យមសិក្សា ការងារយុវជន ការងារកីឡា និងការងារផ្សេងទៀតដែលបានធ្វើប្រតិភូកម្មមកឱ្យរដ្ឋបាលក្រុង ស្រុក។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ត្រូវបំពេញតួនាទីជាសេនាធិការឱ្យក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក និងមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផលចំពោះក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក។

នាយក ឬប្រធានគណៈគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដែលជាប្រតិបត្តិករផ្ទាល់ ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផលចំពោះការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពក្នុងការគ្រប់គ្រងសាច់ប្រាក់ និងការចំណាយ ស្របតាមគោលការណ៍ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងតម្លាភាព។

**ប្រការ ៥.-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ដោយមានការិយាល័យអប់រំ យុវជន និងកីឡា ជាសេនាធិការ ត្រូវរៀបចំផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលត្រូវបានប្រគល់។

នៅក្នុងដំណាក់កាលនៃការរៀបចំថវិកា ដោយផ្អែកលើផែនការសកម្មភាពប្រចាំឆ្នាំ និងក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ត្រូវដឹកនាំ និងណែនាំការិយាល័យអប់រំ យុវជន និងកីឡា ឱ្យរៀបចំគម្រោងថវិកាប្រចាំឆ្នាំស្របតាមលក្ខខណ្ឌនានា និងតាមនីតិវិធីហិរញ្ញវត្ថុជា

ធរមាន និងស្របតាមសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ដើម្បីដាក់ជូនគណៈអភិបាល និងក្រុមប្រឹក្សាក្រុង ស្រុក ពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា។

នៅក្នុងដំណាក់កាលនៃការអនុវត្តថវិកា អភិបាលនៃគណៈអភិបាលក្រុង ស្រុក គឺជាអាណាប័កដើមខ្សែនៃថវិកាក្នុងការបញ្ជាប្រតិបត្តិការចំណូល និងធ្វើប្រតិបត្តិការចំណាយថវិកាក្នុងវង់ឥណទានថវិការបស់ខ្លួន។ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ដែលមានការិយាល័យអប់រំ យុវជន និងកីឡាជាសេនាធិការ ត្រូវរៀបចំ និងអនុវត្តថវិកាឱ្យស្របតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ និងនីតិវិធីអនុវត្តស្តីពីការរៀបចំ និងការអនុវត្តថវិកាកម្មវិធី។ គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា ដែលទទួលសាច់ប្រាក់ពីរតនាគារខេត្ត តាមរយៈគណនីធនាគាររបស់ខ្លួន ត្រូវអនុវត្តចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងតម្លាភាព។ មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ដែលទទួលសាច់ប្រាក់ពីរដ្ឋបាលក្រុង ស្រុក តាមរយៈការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារ ត្រូវអនុវត្តចំណាយស្របតាមគោលការណ៍ហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងតម្លាភាព។

## ជំពូកទី ៣
## ការរៀបចំគម្រោងថវិកា

**ប្រការ ៦.-**

កញ្ចប់ថវិកា រួមទាំងចំណាយបន្ទុកបុគ្គលិក សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ត្រូវបានគ្រោងជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ពិភាក្សាភ្ជាប់គ្នាជាមួយនឹងគម្រោងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងរដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងក្នុងក្របខណ្ឌថវិកាវិស័យអប់រំ ព្រមទាំងក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយជាក់លាក់នៃវិស័យអប់រំ។

ដើម្បីធានាដល់ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព នៅក្នុងត្រីមាសទី ១ នៃឆ្នាំនីមួយៗ រដ្ឋបាលក្រុង ស្រុក ត្រូវលើកសំណើជូនក្រសួងអប់រំ យុវជន និងកីឡា

តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា អំពីតម្រូវការគ្រូបង្រៀន និងតម្រូវការនៃការបណ្ដុះបណ្ដាលគ្រូនៅតាមសាលារៀន មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងនៅតាមមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ស្របតាមផែនការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យអប់រំ ការជ្រើសរើស និងការបែងចែកគ្រូ រួមទាំងការផ្ដល់ការបណ្ដុះបណ្ដាលមូលដ្ឋាន និងការបណ្ដុះ-បណ្ដាលបន្ត។

កញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច និងការអប់រំបឋមសិក្សានៃរដ្ឋបាលក្រុង ស្រុក ត្រូវគ្រោងផ្អែកតាមមុខសញ្ញាចំណាយ និងរូបមន្តក្នុងការគណនា និងបែងចែកធនធានក្នុងក្របខណ្ឌនៃថវិកាដំណើរការសាលារៀនសាធារណៈ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគោលការណ៍ណែនាំ ស្ដីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដោយឡែកកញ្ចប់ថវិកាសម្រាប់អនុវត្តមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ត្រូវបានគ្រោងទៅតាមលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍នានាជាធរមាន។

**ប្រការ ៧.-**

ដំណើរការនៃការរៀបចំថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក និងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងរដ្ឋបាលកណ្ដាលនៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំរួមគ្នា ស្របតាមប្រតិទិននៃការរៀបចំថវិកាថ្នាក់ជាតិប្រចាំឆ្នាំ ទាំងក្នុងដំណាក់កាលរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងដំណាក់កាលរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីធានាសង្គតិភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយវិស័យអប់រំ។

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ត្រូវទទួលបន្ទុកសម្របសម្រួល ប្រមូលសរុប និងរៀបចំគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ក្នុងក្របខណ្ឌថវិកាកម្មវិធីក្រោមការដឹកនាំ និងការណែនាំរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក និងដោយមានការគាំទ្រផ្នែកបច្ចេកទេសពីមន្ទីរអប់រំ យុវជន និងកីឡា រួចបញ្ជូនទៅសុំការពិនិត្យ និងឯកភាពពីគណៈអភិបាលក្រុង ស្រុក មុននឹងដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សាក្រុង ស្រុក អភិបាលនៃគណៈ-អភិបាលក្រុង ស្រុក ត្រូវបញ្ជូនសំណើគម្រោងថវិកានេះ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡា ជូនក្រសួងអប់រំ យុវជន និងកីឡា ១ (មួយ) ច្បាប់ ដើម្បីពិនិត្យសង្គតិភាពឱ្យស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ បែបបទនៃការរៀបចំផែនការសកម្មភាពអប់រំ យុវជន និងកីឡា និងរចនាសម្ព័ន្ធកម្មវិធីដែលកំណត់

ដោយក្រសួងអប់រំ យុវជន និងកីឡា និង ១ (មួយ) ច្បាប់ទៀតជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យការផ្សារភ្ជាប់គម្រោងថវិកានេះ ជាមួយគម្រោងថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាទាំងមូល។

សំណើគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក នឹងត្រូវដាក់ពិភាក្សាការពាររួមគ្នា ជាមួយនឹងសំណើគម្រោងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា និងថវិការដ្ឋបាលកណ្ដាលនៃក្រសួងអប់រំ យុវជន និងកីឡា។ កិច្ចពិភាក្សាការពារគម្រោងថវិកានេះ នឹងប្រព្រឹត្តទៅជា ២ កម្រិត រួមមាន កម្រិតបច្ចេកទេស ដែលត្រូវរៀបចំ និងដឹកនាំដោយថ្នាក់ដឹកនាំអគ្គនាយកដ្ឋានថវិកា និងកម្រិតថ្នាក់ដឹកនាំក្រសួង ស្ថាប័នដែលត្រូវដឹកនាំដោយថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យផ្ដល់កញ្ចប់ថវិកាទៅតាមលទ្ធភាពថវិកាជាតិប្រចាំឆ្នាំ ក្នុងក្របខណ្ឌថវិកាវិស័យអប់រំ និងក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី ព្រមទាំងក្នុងក្របខណ្ឌនៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ ដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយជាក់លាក់នៃវិស័យអប់រំ។

គម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ត្រូវផ្ដល់ជូនផ្អែកតាមរូបមន្តក្នុងការគណនា និងការបែងចែកធនធានក្នុងក្របខណ្ឌនៃថវិកាដំណើរការសាលារៀនសាធារណៈ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ព្រមទាំងស្របតាមលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍នានាជាធរមានពាក់ព័ន្ធនឹងការគ្រោងថវិកាសម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ។

ក្នុងករណីមានការសម្រេចដោយឡែកពាក់ព័ន្ធនឹងការកាត់បន្ថយ ឬ បង្កើនទំហំថវិកាទៅតាមលទ្ធភាព និងភាពទ្រទ្រង់បាននៃថវិកាប្រចាំឆ្នាំលើសំណើគម្រោងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ រដ្ឋបាលក្រុង ស្រុកនឹងត្រូវទទួលបានការជូនដំណឹងនេះជាលាយលក្ខណ៍អក្សរពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៨.-**

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ដែលត្រូវបានអនុម័តដោយច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ គឺជាឧបសម្ព័ន្ធថវិកាសម្រាប់រដ្ឋបាលក្រុង ស្រុក នឹងត្រូវបានរៀបចំលម្អិតជាសៀវភៅថវិកា តាមការកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ជូនទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ដើម្បីអនុវត្ត និងសម្រាប់ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ព្រមទាំងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីតាមដានការអនុវត្តក្នុងក្របខណ្ឌវិស័យអប់រំ។

បន្ថែមពីលើធនធានហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ដែលទទួលបានពីថវិកាថ្នាក់ជាតិ តាមលទ្ធភាពថវិកាប្រចាំឆ្នាំក្នុងក្របខណ្ឌនៃកញ្ចប់ថវិកាវិស័យអប់រំ រដ្ឋបាលក្រុង ស្រុកអាចប្រើប្រាស់ចំណែកធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់គាំទ្រដល់ការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ដែលបានប្រគល់។

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការ-អប់រំក្រៅប្រព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ដែលត្រូវបានបែងចែកលម្អិតទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកាដូចមានចែងក្នុងសៀវភៅថវិកា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានផ្ទេរជូនរដ្ឋបាលក្រុង ស្រុក ដើម្បីអនុវត្តឱ្យបានទាន់ពេលវេលាចាប់ពីថ្ងៃទី០១ ខែមករា នៃឆ្នាំសារពើពន្ធនីមួយៗ។

## ជំពូកទី ៤
## នីតិវិធីនៃការអនុវត្តថវិកា
## ផ្នែកទី១
## ការបើកសាច់ប្រាក់

### ប្រការ ៩.-

ថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ត្រូវធ្វើការបើកផ្តល់សាច់ប្រាក់មុន។

ការបើកផ្តល់សាច់ប្រាក់មុន គឺជានីតិវិធីដែលតម្រូវឱ្យផ្តល់សាច់ប្រាក់ជាមុនចំនួន ១០០% (មួយរយភាគរយ) ដែលត្រូវបើកផ្តល់ចំនួន ០២ (ពីរ) លើកក្នុង ១ឆ្នាំ គឺលើកទី១ នៅដើមខែមករា និងលើកទី២ នៅដើមខែមិថុនា នៃឆ្នាំនីមួយៗ តាមកម្មវិធីចំណាយសាច់ប្រាក់។

### ប្រការ ១០.-

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ត្រូវរៀបចំសំណើសុំបើកសាច់ប្រាក់មុន សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដោយភ្ជាប់មកជាមួយនូវកម្មវិធីចំណាយសាច់ប្រាក់ តាមរយៈការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ពិនិត្យ និងសម្រេច រួចបញ្ជូនទៅរតនាគារខេត្ត ដើម្បីអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន។

**ប្រការ ១១.-**

រតនាគារខេត្ត ត្រូវបង្វែរសាច់ប្រាក់ចូលគណនីធនាគាររបស់គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា នៅដើមខែមករា និងដើមខែមិថុនា ទៅតាមកម្មវិធីចំណាយសាច់ប្រាក់ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

ដោយឡែក រតនាគារខេត្ត ត្រូវបង្វែរសាច់ប្រាក់ជូនរដ្ឋបាលក្រុង ស្រុក សម្រាប់អនុវត្តមុខងារការអប់រំក្រៅប្រព័ន្ធ ទៅតាមកម្មវិធីចំណាយសាច់ប្រាក់ ដោយប្រើប្រាស់ប្រព័ន្ធធនាគារ។

រដ្ឋបាលក្រុង ស្រុក ត្រូវបានអនុញ្ញាតឱ្យបើកគណនីនៅតាមធនាគារដៃគូដើម្បីទទួលសាច់ប្រាក់សម្រាប់អនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ។

រដ្ឋបាលក្រុង ស្រុក ត្រូវអនុញ្ញាតឱ្យគ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា បន្តប្រើប្រាស់គណនីនៅធនាគារដៃគូដែលមានស្រាប់ ដើម្បីប្រតិបត្តិការសាច់ប្រាក់របស់ខ្លួន។ ដោយឡែក គ្រឹះស្ថានសិក្សាដែលនឹងត្រូវបង្កើតថ្មី ត្រូវបើកគណនីនៅតាមធនាគារដៃគូស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ផ្នែកទី២
## ការគ្រប់គ្រងសាច់ប្រាក់

**ប្រការ ១២.-**

នៅពេលដែលបានទទួលសាច់ប្រាក់ គ្រប់គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវប្រជុំផ្សព្វផ្សាយ និងបិទផ្សាយលើបញ្ជរព័ត៌មានជូនដល់លោកគ្រូ អ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធផ្សេងទៀត នូវព័ត៌មានអំពីចំនួនទឹកប្រាក់ដែលបានទទួល និងគម្រោងចំណាយប្រចាំត្រីមាស។

**ប្រការ ១៣.-**

គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (គ.ម.ស) របស់គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន (គ.គ.ស) ត្រូវសហការចាត់ចែងគ្រប់គ្រង និងទទួលខុសត្រូវលើចំណាយថវិការបស់អង្គភាពខ្លួនប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

នាយក ឬប្រធានគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវគ្រប់គ្រង និងទទួលខុសត្រូវលើការចំណាយថវិការបស់អង្គភាពខ្លួនប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។

## ផ្នែកទី៣
## ការទូទាត់ និងកិច្ចបញ្ជិកាគណនេយ្យ

**ប្រការ ១៤.-**

ហេរញ្ញិករបស់គ្រឹះស្ថានមត្តេយ្យសិក្សា និងគ្រឹះស្ថានបឋមសិក្សា ត្រូវប្រមូលឯកសារ លិខិតយុត្តិការ និងប្រមូលសក្ខីបត្រចំណាយរួមមាន÷ លិខិតស្នើសុំថវិកា វិក្កយបត្រ ឬសក្ខីបត្រចំណាយផ្សេងៗ និងប័ណ្ណចំណាយ ដើម្បីរៀបចំរបាយការណ៍ទូទាត់ចំណាយថវិកាតាមជំពូក គណនី និងអនុគណនី ជូនទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក។ លិខិតយុត្តិការ និងសក្ខីបត្រច្បាប់ដើមទាំងនោះ ត្រូវរក្សាទុកនៅអង្គភាពដើមសម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយចំណាយ។

ហេរញ្ញិករបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវប្រមូលឯកសារ លិខិតយុត្តិការ និងសក្ខីបត្រចំណាយ ដើម្បីរៀបចំរបាយការណ៍ចំណាយមកការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក។

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ត្រូវប្រមូលរបាយការណ៍ទូទាត់ចំណាយថវិកាពីគ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗនៅតាមក្រុង ស្រុក ដើម្បីរៀបចំបូកសរុបជាតារាងរបាយការណ៍ទូទាត់ចំណាយថវិកាតាមជំពូក គណនី អនុគណនី រួចជូនទៅការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក។ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំបោះផ្សាយអាណត្តិនិយ័តកម្ម ដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ចុះហត្ថលេខា រួចបញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ដើម្បីពិនិត្យ និងចុះហត្ថលេខាក្នុងនាមអភិបាលហិរញ្ញវត្ថុ មុននឹងបញ្ជូនទៅរតនាគារខេត្ត ដើម្បីពិនិត្យ និងទូទាត់ជម្រះបញ្ជី ដោយភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម÷

- លិខិតស្នើសុំទូទាត់ថវិកា
- សាលាកប័ត្រកត់ត្រាចំណាយនិងត្រួតពិនិត្យហិរញ្ញវត្ថុ
- ដីកាអមលិខិតយុត្តិការ
- ដីកាអមបញ្ចេញអាណត្តិនិយ័តកម្ម

- អាណត្តិនិយ័តកម្ម
- និងរបាយការណ៍ទូទាត់ចំណាយថវិកា (ជំពូក គណនី អនុគណនី)។

**ប្រការ ១៥.-**

គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ មិនអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់នៅសល់ចុងឆ្នាំសម្រាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ។ ក្នុងករណីមានសាច់ប្រាក់នៅសល់ចុងឆ្នាំ គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវបង់ប្រាក់ចូលគណនីធនាគាររបស់រតនាគារខេត្តវិញ យ៉ាងយូរថ្ងៃទី២៥ ខែធ្នូ នៃឆ្នាំនីមួយៗ ហើយយកប្រកាសពីធនាគារបញ្ជូនទៅការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីបូកសរុប និងបញ្ជូនទៅរដ្ឋបាលក្រុង ស្រុក ដើម្បីរៀបចំសំណើបង់សាច់ប្រាក់សល់ពីការបើកផ្តល់មុន។

**ប្រការ ១៦.-**

គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវកត់ត្រាចំណូលចំណាយ ក្នុងកិច្ចបញ្ជិកាគណនេយ្យដូចខាងក្រោម÷

- កិច្ចបញ្ជិកាគណនេយ្យហិរញ្ញវត្ថុ (បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ ប័ណ្ណចំណូល ប័ណ្ណចំណាយ និងបញ្ជីបេឡា)
- កិច្ចបញ្ជិកាគណនេយ្យសម្ភារ (ប័ណ្ណបញ្ចូលសម្ភារទំនិញ ប័ណ្ណបញ្ចេញសម្ភារទំនិញ និងបញ្ជីវិភាគសម្ភារទំនិញ)។

## ផ្នែកទី៤
## ការរៀបចំរបាយការណ៍សមិទ្ធកម្ម

**ប្រការ ១៧.-**

គ្រឹះស្ថានមត្តេយ្យសិក្សា គ្រឹះស្ថានបឋមសិក្សា មជ្ឈមណ្ឌលសិក្សាសហគមន៍ ឬមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមណ្ឌលសមស្របដែលអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗ ត្រូវរៀបចំ និងបញ្ជូនរបាយការណ៍សមិទ្ធកម្មប្រចាំឆមាស និងប្រចាំឆ្នាំទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក

ដើម្បីបូកសរុប និងបញ្ជូនមកការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងដាក់ជូនគណៈអភិបាលក្រុង ស្រុក ពិនិត្យសម្រេច មុនដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ពិនិត្យអនុម័ត។

របាយការណ៍សមិទ្ធកម្ម ត្រូវផ្ញើជូនរដ្ឋបាលខេត្ត មួយ (១) ច្បាប់ និងជូនមន្ទីរអប់រំ យុវជន និងកីឡា មួយ(១) ច្បាប់ ដើម្បីបូកសរុប និងផ្ញើជូនក្រសួងអប់រំ យុវជន និងកីឡា ឱ្យទាន់ពេលវេលាកំណត់។

## ជំពូកទី ៥

## អន្តរប្បញ្ញត្តិ

**ប្រការ ១៨.-**

ឥណទានថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការ-អប់រំក្រៅប្រព័ន្ធដែលអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ នៅរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបង ត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ទន្ទឹមនេះ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពខាងលទ្ធផលចំពោះក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក លើការអនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រកាសអន្តរក្រសួងនេះ។

ប្រកាសអន្តរក្រសួងនេះ ត្រូវចាប់ផ្តើមអនុវត្តពេញលេញនៅតាមរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបងចាប់ពីឆ្នាំ២០២១ តទៅ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២០.-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ព្រមទាំងគ្រប់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុកទាំង១៤ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង

ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកទាំង១៤ និងអង្គភាពក្រោមឱវាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១០រោច ខែ ជេស្ឋ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០

| | | |
|---|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងមហាផ្ទៃ** | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងអប់រំ យុវជន និងកីឡា** |
| **សម្តេចក្រឡាហោម ស ខេង** | **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** |

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រដ្ឋបាលខេត្តបាត់ដំបង
- ដូចប្រការ ២០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ